# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ
# ជូនបូស្តុទឹកថ្លា ថ្ងៃទី០២ ខែមករា ឆ្នាំ២០២០
# តើខ្ញុំជានរណា?

**អត្ថបទទី១៖ យ៉ូហានទី១ ២,២២-២៨**

អ្នកណាមិនទទួលស្គាល់ព្រះបុត្រា អ្នកនោះក៏គ្មានព្រះបិតាគង់ជាមួយដែរ រីឯអ្នកដែលទទួលស្គាល់ព្រះបុត្រា ទើបមានព្រះបិតាគង់ជាមួយ។ ១យហ ២,២៣

**ដំណឹងល្អ៖ យ៉ូហាន ១,១៩-២៨**

លោកយ៉ូហានមានប្រសាសន៍ថា៖ «ខ្ញុំជាសំឡេងបុរសម្នាក់ដែលស្រែក នៅវាលរហោស្ថានថា: "ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់" ត្រូវនឹងសេចក្ដីដែលព្យាការីអេសាយបានថ្លែងទុកមក»។ យហ ១,២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងនឹកឃើញសំណួរដែលគេសួរទៅលោកយ៉ូហានបាទីស្ដ **"តើលោកជានរណា?"** ដោយសារគេច្រឡំលោកយ៉ូហានបាទីស្ដជាព្រះយេស៊ូ។ ប៉ុន្តែ គាត់ឆ្លើយច្បាស់ **"ខ្ញុំរៀបចំផ្លូវថ្វាយព្រះយេស៊ូមែន តែខ្ញុំមិនមែនជាព្រះយេស៊ូទេ"**។ ថ្ងៃនេះ ជាឱកាសមួយសម្រាប់យើងពិចារណា **តើយើងជានរណា?** ច្បាស់ហើយយើងមិនមែនជាព្រះយេស៊ូ យើងរៀងៗខ្លួន យ៉ូសែបក្ដី ម៉ារីក្ដី ហោរាចារ្យក្ដី គ្រូគង្វាលក្ដី និងយើងទាំងអស់ដែលមានឈ្មោះរៀងៗខ្លួនក្ដី យើងត្រូវតែសួរសំណួរនេះ **"នៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់យើងផ្ទាល់ តើយើងជានរណា? តើព្រះជាម្ចាស់បានរៀបចំអ្វីខ្លះនៅក្នុងជីវិតខ្ញុំ ដើម្បីឲ្យខ្ញុំរកឃើញសុភមង្គលដែលព្រះជាម្ចាស់ចង់ឲ្យខ្ញុំមាន?"**។ ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យមានសុភមង្គល ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃមនុស្សយើងរៀបចំសុទ្ធតែអំពើឃោរឃៅ និងសកម្មភាពផ្សេងៗ ដែលណែនាំឲ្យសម្ពន្ធមេត្រីរវាងព្រះជាម្ចាស់និងយើងដាច់។ ហេតុនេះហើយ ព្រះជាម្ចាស់បានចាត់ព្រះបុត្រាឲ្យយាងមក ដើម្បីឲ្យមនុស្សយើងទាំងអស់រកឃើញសុភមង្គលដ៏ពិតប្រាកដ។ ប៉ុន្តែ ដើម្បីរកឃើញសុភមង្គលដ៏ពិតប្រាកដនេះ យើងត្រូវការគិតពិចារណា នៅក្នុងជីវិតខ្ញុំព្រះជាម្ចាស់មានគម្រោងការអ្វីខ្លះ ដើម្បីឲ្យខ្ញុំឆ្លើយដូចលោកយ៉ូហានបាទីស្ដ "ខ្ញុំជាអ្នកដែលរៀបចំផ្លូវថ្វាយព្រះជាម្ចាស់"។

ម្យ៉ាងទៀត មិនមែនតែគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់យើង យើងត្រូវការបើកភ្នែកដើម្បីមើលឃើញសញ្ញាសម្គាល់នៅក្នុងជីវិតរបស់យើងប្រចាំ ដើម្បីយល់អំពីគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់យើង។ បើយើងនៅអង្គុយបិទភ្នែក បិទត្រចៀក យើងមិនព្រមបើកភ្នែកយ៉ាងច្បាស់ដើម្បីមើលសញ្ញាសម្គាល់ យើងធ្វើដូចម្ដេចដើម្បីបំពេញគម្រោងការរបស់ព្រះជាម្ចាស់ដែល

បានរៀបចំសម្រាប់យើង។ ព្រះនាងម៉ារី មិនបានដឹងពីគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់គាត់ទេ ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃគាត់ធ្វើអ្វីដែលឪពុកម្តាយបានរៀបចំឲ្យគាត់ ទាំងអធិដ្ឋាន ទាំងធ្វើជាយុវនារីម្នាក់ដែលរស់នៅក្នុងផ្ទះ។ នៅពេលទេវទូតកាព្រីអែលមក នៅពេលនោះព្រះនាងម៉ារីមើលសញ្ញាសម្គាល់មួយ ពេលព្រះយេស៊ូប្រសូតព្រះនាងម៉ារីឃើញទាំងគ្រូគង្វាល ទាំងទេវទូតទាំងហោរាចារ្យ ណែនាំឲ្យព្រះនាងម៉ារីនឹកឃើញនូវអ្វីដែលទេវទូតកាព្រីអែលបានប្រាប់គាត់។ ប៉ុន្តែ ព្រះនាងម៉ារីមិនទៅផ្សព្វផ្សាយ ព្រះនាងម៉ារីទុកនៅក្នុងដួងចិត្តរបស់គាត់ សញ្ញាដែលគាត់ឃើញជាក់ស្តែង ដើម្បីចូលយ៉ាងជ្រៅនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ ដែលបានរៀបចំទុកឲ្យព្រះនាងម៉ារី។ ក្រោយមក ព្រះនាងម៉ារីធ្វើដំណើរជាមួយព្រះយេស៊ូដល់មង្គលការកាណាព្រះនាងម៉ារីមើលសញ្ញា ពេលព្រះយេស៊ូសោយទិវង្គតព្រះនាងម៉ារីនៅក្បែរឈើឆ្កាងមើលសញ្ញាមួយទៀតរហូតដល់ព្រះនាងម៉ារីចូលនៅស្ថានបរមសុខតែម្តង។ ព្រះនាងម៉ារី បានបំពេញគម្រោងការរបស់ព្រះជាម្ចាស់ ពីមួយថ្ងៃទៅមួយថ្ងៃនៅក្នុងជីវិតព្រះនាងផ្ទាល់ ដោយមើលឃើញសញ្ញាសម្គាល់ដែលព្រះជាម្ចាស់រៀបចំឲ្យដើម្បីឲ្យគាត់យល់។

លោកយ៉ូសែបក៏ដូចគ្នាដែរ គាត់មានគម្រោងការធម្មតានៅក្នុងជីវិតគាត់ស្រឡាញ់នាងម៉ារីចង់រៀបការ ក្រោយមកទទួលដំណឹងថាព្រះនាងម៉ារីមានផ្ទៃពោះ ប៉ុន្តែគាត់ចេះមើលសញ្ញាសម្គាល់ដែលព្រះជាម្ចាស់រៀបចំឲ្យគាត់។ នៅពេលទេវទូតនិយាយទៅគាត់ គាត់យល់ថានេះជាគម្រោងការរបស់ព្រះជាម្ចាស់ ហេតុនេះហើយខ្ញុំមិនបណ្តេញព្រះនាងម៉ារីទេ ខ្ញុំយកព្រះនាងម៉ារីធ្វើជាប្រពន្ធនិងថែរក្សាព្រះនាងម៉ារី ដោយធ្វើជាប្តីដ៏ល្អ ថែរក្សាកូនដែលទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ដូច្នេះ នៅក្នុងជីវិតរបស់យើង យើងជួបជួនកាលជាមួយបូជាចារ្យ ជួនកាលជាមួយបងប្រុសបងស្រី ជួនកាលជាមួយបងប្អូន ជួនកាលជាមួយមនុស្សម្នាក់ ដែលទៅជាសញ្ញាមួយណែនាំឲ្យយើងយល់អំពីគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើងផ្ទាល់។ នៅក្នុងឆ្នាំ ២០២០ ណែនាំឲ្យយើងមើលឃើញគម្រោងការរបស់ព្រះជាម្ចាស់។

ខ្ញុំជូនពរបងប្អូនទាំងអស់ ចូលនៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលបានរៀបចំសញ្ញាយ៉ាងច្រើននៅក្នុងជីវិតរបស់យើង។ ប៉ុន្តែ យើងត្រូវបើកភ្នែកដើម្បីមើលឃើញគម្រោងការពិសេសសម្រាប់ខ្ញុំផ្ទាល់ដែលព្រះជាម្ចាស់បានរៀបចំ ដោយដឹងថាសម្រាប់ខ្ញុំផ្ទាល់គម្រោងការពិសេសនេះជាគម្រោងការអស្ចារ្យ។ ថ្ងៃនេះ ជាឱកាសមួយដើម្បីអធិដ្ឋានឲ្យឆ្នាំ ២០២០នេះ យើងអាចរកឃើញ ខ្ញុំជានរណា? និងតួនាទីខ្ញុំជាអ្វីនៅក្នុងព្រះសហគមន៍ និងនៅក្នុងសង្គម ដើម្បីចូលយ៉ាងជ្រៅនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ដែលបានរៀបចំសម្រាប់ខ្ញុំ។ យើងអធិដ្ឋាន ទូលអង្វរព្រះជាម្ចាស់ប្រទានពរដល់យើងរៀងៗខ្លួន អរព្រះគុណព្រះជាម្ចាស់

សម្រាប់ព្រះយេស៊ូដែលប្រសូតហើយ សម្រាប់អំណារដែលយើងបានទទួលរួមជាមួយទេវទូតទាំងឡាយ។ អាមែន!